រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន
# ដំណើរអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីទស្សនកិច្ច និងបញ្ចុះបឋមសិលាជានិមិត្តរូបនៅអគារអនុវត្តមុខងារសេសសល់ របស់អ.វ.ត.ក.

នាព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតទស្សនកិច្ចនៅអគារអនុវត្តមុខងារសេសសល់របស់អ.វ.ត.ក. និងបញ្ចុះបឋមសិលាជានិមិត្តរូបក្នុងការចាប់ផ្តើមសាងសង់បន្ទប់ពិគ្រោះយោបល់សម្រាប់ជនរងគ្រោះ សាលតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីពីដំណើរការជំនុំជម្រះក្តី និងឧទ្យានសម្រាប់ការចងចាំនៅក្នុងអគារអនុវត្តមុខងារសេសសល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ដែលមានអាសយដ្ឋានស្ថិតនៅអគារលេខ៤០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## ការណែនាំសម្រាប់សារព័ត៌មាន

សម្រាប់តំណាងសារព័ត៌មានទាំងឡាយដែលមានបំណងអញ្ជើញមករាយការណ៍ព័ត៌មានដោយផ្ទាល់ពីកម្មវិធីនេះ ត្រូវស្នើសុំចុះឈ្មោះតាមរយៈលេខទូរស័ព្ទ ឬតេលេក្រាម 066 259 898 ឬអ៊ីមែល YAR.Rorsart@eccc.gov.kh ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់**ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង១២៖០០ ថ្ងៃត្រង់**។

#####

## កំណត់ចំណាំចំពោះបណ្ណាធិការព័ត៌មាន
## សមិទ្ធផលរបស់ អ.វ.ត.ក. ពីខែមករា ឆ្នាំ២០២៣ ដល់ខែមិថុនា ឆ្នាំ២០២៤

ផ្អែកតាមស្មារតី«កិច្ចព្រមព្រៀងបន្ថែមស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ» នៅឆ្នាំ២០២១ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ អ.វ.ត.ក. ត្រូវបានផ្តល់អាណត្តិឱ្យអនុវត្តមុខងារសេសសល់ដែលរួមមានមុខងារគតិយុត្តិយុត្តាធិការនិងមុខងារមិនមែនយុត្តាធិការ សម្រាប់រយៈពេល៣

ឆ្នាំដំបូងពីឆ្នាំ២០២៣ ដល់២០២៥។ ចាប់ពីដើមឆ្នាំ២០២៣រហូតដល់នេះ ភាគីជាតិនិងភាគីអន្តរជាតិនៃអ.វ.ត.ក. បានចាប់ផ្តើមអនុវត្តមុខងារសេសសល់របស់ខ្លួននៅឆ្នាំទី១ និងសម្រេចបាននូវសមិទ្ធផលការងារសំខាន់ៗជាច្រើន រួមមាន៖

ទី១-បានផ្ទេរពិរុទ្ធជន ខៀវ សំផន ដែលបច្ចុប្បន្នមានអាយុ៩៤ឆ្នាំ ទៅអនុវត្តទោសអស់មួយជីវិតនៅពន្ធនាគារខេត្តកណ្តាលកាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ ក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ។ បច្ចុប្បន្ន អ.វ.ត.ក. បាននិងកំពុងតាមដានការអនុវត្តទោសចំពោះពិរុទ្ធជននេះជាមួយគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម (ICRC) ដោយផ្អែកលើបទដ្ឋាននិងទម្លាប់អនុវត្តជាអន្តរជាតិ ព្រមទាំងស្មារតីនៃកិច្ចព្រមព្រៀងបន្ថែមខាងលើ។

ទី២-បានបំពេញកាតព្វកិច្ចដូចបានតម្រូវឱ្យអនុវត្តនៅក្នុងសាលដីកាស្ថាពរ នៃសំណុំរឿង០០២/០២ ក្នុង ការជូនដំណឹងអំពីបច្ចុប្បន្នភាពនៃសមិទ្ធផលការងារសម្រេចបាននិងការអនុវត្តមុខងារសេសសល់របស់ អ.វ.ត.ក. ដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រមាណ ៣ ១០០ នាក់ ស្មើនឹង៨០% នៃដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៣ ៨៧៥នាក់ ដែលបាននិងកំពុងរស់នៅក្នុង២៥ រាជធានី ខេត្ត។

ទី៣-បានធ្វើចំណាត់ថ្នាក់ពីប្រភេទឯកសារសម្ងាត់បំផុតនិងសម្ងាត់ ទៅជាឯកសារសាធារណៈនៃឯកសារសំណុំរឿង ០០២ បានចំនួនប្រមាណ២២ម៉ឺនទំព័រ និងកំពុងពិនិត្យមើលឯកសារសំណុំរឿងដ៏ទៃទៀតដែលនៅសល់ប្រមាណជា២លានទំព័រទៀត សម្រាប់ធ្វើការផ្សព្វផ្សាយជាសាធារណៈ។

ទី៤-បានរៀបចំនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ «មជ្ឈមណ្ឌលធនធានរបស់អ.វ.ត.ក.» កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ។ មជ្ឈមណ្ឌលធនធាននេះ រួមមានសមាសភាគចំនួនប្រាំមួយ ក្នុងនោះសមាសភាគចំនួនបួនត្រូវបានកសាងរួចរាល់និងកំពុងដាក់ឱ្យដំណើរការរួចហើយ ដែលរួមមាន (ទី១). បណ្ណាល័យនិងកន្លែងស្រាវជ្រាវ, (ទី២). និហិតដ្ឋានបណ្ណសារ (Archives Repository), (ទី៣). បន្ទប់ប្រើប្រាស់ពហុបំណងសម្រាប់រៀបចំសិក្ខាសាលា កិច្ចប្រជុំ និងតុលាការត្រាប់ (Moot Court), និង (ទី៤). គេហទំព័រថ្មីដែលមានលក្ខណៈអន្តរកម្ម (interactive features) របស់អ.វ.ត.ក.។ រីឯគម្រោងការងារចំនួនពីរទៀត រួមមាន (ទី១). ការសាងសង់បន្ទប់ពិគ្រោះយោបល់សម្រាប់ជនរងគ្រោះ និងសាលតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីពីដំណើរការជំនុំជម្រះក្តី, និង(ទី២). ឧទ្យានសម្រាប់ការចងចាំ គ្រោងនឹងសាងសង់បញ្ចប់នៅឆ្នាំ២០២៤ និងឆ្នាំ២០២៥។

ទី៥-បាននិងកំពុងរៀបចំដំណើរទស្សនកិច្ចសិក្សា២លើកក្នុងមួយសប្តាហ៍ ដល់សាធារណជន ជាពិសេស យុវជន យុវនារី សិស្ស និស្សិត និងគ្រូបង្រៀនដែលមានអ្នកចូលរួមសរុបប្រមាណ ៤០ ២៩៣នាក់ ចាប់ពីខែមករា ឆ្នាំ២០២៣ រហូតមកទល់ខែមិថុនា ឆ្នាំ២០២៤។ អ្នកចូលរួមកម្មវិធីនេះ ត្រូវបានពន្យល់អំពីដំណើរការ និងសមិទ្ធផលសម្រេចបាន

របស់អ.វ.ត.ក., ទៅទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង, សារមន្ទីរវាលពិឃាតជើងឯក, និងវិមានឈ្នះ ឈ្នះរបស់រាជរដ្ឋាភិបាល។

ទី៦-បានផលិតវីដេអូខ្លីៗទៅលើប្រធានបទជាច្រើន ទាក់ទងទៅនឹងអាណត្តិនិងការងារប្រតិបត្តិការរបស់អ.វ.ត.ក. និងជាពិសេសសបានផលិត «កម្មវិធីវីដេអូខ្លីអប់រំនិងផ្សព្វផ្សាយជាស៊េរី» ចំនួនសរុប៤២ភាគដែលមានទម្រង់ជាលក្ខណៈសំណួរនិងចម្លើយទាក់ទងនឹងការបង្កើតនិងដំណើរការកាត់សេចក្ដីនៃគ្រប់សំណុំរឿងចំនួន៧ទាំងអស់អ.វ.ត.ក.។ កម្មវិធីនេះ មានគោលបំណងពង្រីកការយល់ដឹងជាលក្ខណៈសម្រាយឬស្រួលយល់ដល់យុវជនកម្ពុជា ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរនិងអំពើសាហាវយង់ឃ្នងនៃរបបខ្មែរក្រហម តាមរយៈប្រព័ន្ធផ្សព្វផ្សាយប្រជាប្រិយរបស់យុវជន ដូចជា Facebook, Telegram, YouTube, TikTok, Instagram, និងតាមប្រព័ន្ធទូរទស្សន៍ផងដែរ។

ទី៧-បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU)ចំនួន៨ ជាមួយដៃគូជាស្ថាប័នជាតិនិងអន្តរជាតិក្នុងការចែករំលែកនិងផ្លាស់ប្ដូរចំណេះដឹង, ចំណេះធ្វើ, បទពិសោធ, និងយុត្តិសាស្ត្រ (Jurisprudences) របស់អ.វ.ត.ក. ទាក់ទងនឹងយុត្តិធម៌អន្តរកាល (Transitional Justices) ដែលជាយុត្តិធម៌ក្រោយដំណោះស្រាយជម្លោះប្រដាប់អាវុធ និងដំណើរការកាត់សេចក្ដី។